ចំណាប់អារម្មណ៍របស់ខ្ញុំ

នៅពេលដែលខ្ញុំបានអានអត្ថបទទាំងអស់នេះចប់ហើយ ខ្ញុំអារម្មណ៍ថា របបកម្ពុជាប្រជាធិបតេយ្យមានការគាបសង្កត់ ជិះជាន់សេរីភាពពលរដ្ឋ រំលោភសិទ្ធិកុមារ លុបបំបាត់សាសនា វត្តអារាម ព្រះសង្ឃ វប្បធម៌ អរិយធម៌ ជំនឿ ទំនៀមទំលាប់ប្រពៃណី ទីផ្សារ រូបិយវត្ថុ និងការបង្អត់អាហារ សម្លាប់រង្គាល សតិរបស់មេដឹកនាំមិនមែនជាមនុស្ស អមនុស្ស ។

ចំណែកឯបក្សណាស៊ីរបស់អាល្លឺម៉ង់ លោក ហ៊ីត្លែរ [illegible] ការគាបសង្កត់ ជិះជាន់សេរីភាពពលរដ្ឋ រំលោភសិទ្ធិមនុស្ស (ភាវ) បំបាត់សាសនា ទំនៀមទំលាប់ប្រពៃណី ទីផ្សារ រូបិយវត្ថុ ភាពឃោរឃៅលើទាសករ បង្អត់អាហារ និងសម្លាប់ជនជាតិប៉ូឡូញ ។ ក៏ដូចជាប្រទេសនីមួយៗទៀត ដែលត្រូវទទួលរងនូវការវាយប្រហារ ដូចជាប្រទេសអាល្លឺម៉ង់ និងកូរ៉េខាងជើង ជាដើម ។

រឿងដែលសំខាន់ និងរឿងដែលខ្ញុំចាប់អារម្មណ៍ខ្លាំងជាងគេនោះគឺ ចំពោះរបបនីមួយៗដែលមាននៅប្រទេស ប៉ូឡូញ ប្រទេសអាល្លឺម៉ង់ និងប្រទេសកូរ៉េខាងជើងទទួលបាន [illegible] របបដែលខ្មែរទទួលបាន [illegible] អ្នកដឹកនាំរបស់របបនោះគេមិនសម្លាប់ជនជាតិខ្លួនឯងនោះទេ ។ មិនដូចជាអ្នកដឹកនាំរបបខ្មែរក្រហមនោះទេ ខ្មែរសម្លាប់ខ្មែរ ។

ពៅ [illegible]